រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៧២ អយក.ប្រក**

**ស្តីពីការបើក « អនុវិទ្យាល័យ បានយ » ក្នុង**

**ស្រុកព្រៃកប្បាស ខេត្តតាកែវ**

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា**

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំនេះ ទូទៅ ។
- បានឃើញ សារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១ - កំរិត២ ។
- យោងលិខិតលេខ ៩៥០ អយក.ត ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់មន្ទីរអប់រំយុវជននិង កីឡា ខេត្តតាកែវ ដោយមានការឯកភាពពីអភិបាលខេត្តតាកែវ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំយុវជននិងកីឡា ខេត្តតាកែវ បើក អនុវិទ្យាល័យ បានយ ជាផ្លូវការ នៅក្នុងឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ចាប់ ឆ្នាំ សិក្សា ១៩៩៥ - ៩៦ នេះតទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិក ផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣** : នាយក - នាយករង នៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករង នៃអនុវិទ្យាល័យ ។

**ប្រការ ៤** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ នាយកអនុវិទ្យាល័យ បានយ មានភារកិច្ចរៀងៗខ្លួនអនុវត្ត ប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**តុល ឡោះ**

* * *